៧-ឯកឧត្តម ទីវ៉ីន ជាតិ អភិបាលខេត្តឧត្តរមានជ័យ ជាសមាជិក
៨-លោក ទៅ និទ អភិបាលរងទី១ ខេត្តឧត្តរមានជ័យ ជាសមាជិកអចិន្ត្រៃយ៍
៩-លោក ឈុំ នុំ អភិបាលរងទី១ ខេត្តសៀមរាប ជាសមាជិក
១០-លោក អន ស៊ឹ អភិបាលរងទី១ ខេត្តបន្ទាយមានជ័យ ជាសមាជិក

ប្រការ ២ : គណៈកម្មការនេះមានភារកិច្ច :

- សហការជាមួយក្រសួងស្ថាប័ន អាជ្ញាធរខេត្តពាក់ព័ន្ធ ដើម្បីរៀបចំពិធីសម្ពោធ ប្រកាសជាផ្លូវការ ខេត្តឧត្តរមានជ័យឲ្យបានក្នុងអំឡុង ខែ មេសា ឆ្នាំ១៩៩៩ នេះ ។
- សហការជាមួយអាជ្ញាធរ ខេត្តឧត្តរមានជ័យ រៀបចំទីតាំងសាលាខេត្ត សាលាស្រុកសាលាឃុំ និង មូលដ្ឋានគ្រឹះចាំបាច់សំរាប់បំពេញការងារ ។
- សហការជាមួយក្រសួងស្ថាប័ន និង ខេត្តពាក់ព័ន្ធ ផ្ទេរភូមិសាស្ត្រ ចលនទ្រព្យ អចលនទ្រព្យ មន្ត្រីរាជការស៊ីវិល យោធា នគរបាល ឲ្យមកចំណុះខេត្តឧត្តរមានជ័យ ។

ប្រការ ៣ : គណៈកម្មការរៀបចំពិធីសម្ពោធប្រកាសជាផ្លូវការ ខេត្តឧត្តរមានជ័យសិទ្ធិបង្កើតអនុគណៈកម្មការផ្សេងៗ ទៀតសំរាប់ជំនួយការងារ តាមការចាំបាច់ ។

ប្រការ ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួង ស្ថាប័ន និង ខេត្តពាក់ព័ន្ធ និង ឯកឧត្តមដែលមានឈ្មោះក្នុងប្រការ ១ ខាងលើ មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ ដោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
ស.ខ

***

រាជធានីភ្នំពេញ ,ថ្ងៃទី០៩ ខែមេសា ឆ្នាំ ១៩៩៩

## សេចក្តីសំរេចលេខ ៣៦ សសរ

## ស្តីពីការបង្កើតគណៈកម្មការ សំរាប់ដោះស្រាយ បាតុភាព បញ្ហាដីធ្លី នៅខេត្តកំពង់ចាម ខេត្តកំពង់ស្ពឺ និងខេត្តតាកែវ

***

បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

- យោងតាមការចាំបាច់ និង បន្ទាន់របស់រាជរដ្ឋាភិបាល

**សំរេច**

ប្រការ ១ : បង្កើតគណៈកម្មការសំរាប់ដោះស្រាយបញ្ហាបាតុភាព អំពើហិង្សា នៅតាមបណ្តាខេត្តកំពង់ចាម ខេត្តកំពង់ស្ពឺ ខេត្តតាកែវ ដែលមានសមាសភាពដូចខាងក្រោម ៖

១-ឯកឧត្តម ទ៊ុំស ឈឹម អគ្គាធិការរងទី១ រដ្ឋបាល និងនគរបាលក្រសួងមហាផ្ទៃ ប្រធាន

២-ឯកឧត្តម យ៉ាឡុង ឆាន់ ទីប្រឹក្សាឯកឧត្តមទេសរដ្ឋមន្ត្រី សុខ អាន ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី អនុប្រធាន

៣-ឯកឧត្តម ឧត្តមសេនីយ៍ទោ សិទ្ធ ខ៊ី មេបញ្ជាការរងកងទ័ពជើងគោក អនុប្រធាន

៤-ឯកឧត្តម ឧត្តមសេនីយ៍ទោ ទុំ សួងាត ប្រធានខុទ្ទកាល័យអគ្គមេបញ្ជាការ ក.យ.ខ.ភ.ម សមាជិក

៥-ឯកឧត្តម សក់ សេដ្ឋា អគ្គនាយករងរដ្ឋបាលក្រសួងមហាផ្ទៃ សមាជិក

៦-ឯកឧត្តម នុច ទះ ប្រធានអធិការកិច្ចរដ្ឋបាល សមាជិក

៧-ឯកឧត្តមអភិបាលខេត្តកំពង់ចាម ខេត្តកំពង់ស្ពឺ ខេត្ត តាកែវ សមាជិក

៨-អភិបាលស្រុកពាក់ព័ន្ធ សមាជិក

ប្រការ ២ : គណៈកម្មការនេះមានភារកិច្ច ៖

- ចុះស្រាវជ្រាវ និង លើកវិធានការដោះស្រាយអោយមានប្រសិទ្ធភាព នូវរាល់បាតុភាពដែលកើតឡើងតាមបណ្តាខេត្តទាំងបី ។
- ធ្វើរបាយការណ៍ អំពីការដោះស្រាយ និងលទ្ធផលនៃការងារខាងលើជូនរាជរដ្ឋាភិបាល ។

ប្រការ ៣ : សមាជិកនៃគណៈកម្មការទាំងអស់ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ សំរាប់សំរួលការងារ ។

ប្រការ ៤ : បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៥ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គបញ្ជាការកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួងស្ថាប័នពាក់ព័ន្ធ អភិបាលខេត្តកំពង់ចាម ខេត្ត តាកែវ ខេត្តកំពង់ស្ពឺ និងឯកឧត្តម អស់លោកដែលមានឈ្មោះក្នុងប្រការ១ ត្រូវទទួលបន្ទុក អនុវត្តសេចក្តីសំរេចអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ជ.ឧបនាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ស ខេង

★★★